# បច្ចេកទេសបង្កកទឹកជ័រតាមលក្ខណៈគ្រួសារ

*ដោយៈវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា*

## សេចក្ដីផ្ដើម

ការប្រមូលយកជ័រទៅកែច្នៃទៅជាកៅស៊ូស្ងួតធ្វើឡើងក្រោមរូបភាពពីបែប គឺទឹកជ័រ និងជ័រកក។ យោងទៅតាមស្ថានភាពចម្ការកៅស៊ូគ្រួសារ ដែលស្ថិតនៅឆ្ងាយពីរោងចក្រ និងដោយខ្វះមធ្យោបាយដឹកជញ្ជូនទឹកជ័រទាន់ពេលវេលាកសិករអាចយកទឹកជ័រមកបង្កកដោយខ្លួនឯង ព្រោះជាការងារងាយស្រួលរក្សាទុក ដឹកជញ្ជូន និងលក់ដូរ។ គាត់អាចបង្កកទឹកជ័រដោយអាស៊ីត ឬទុកឲ្យកកតាមធម្មជាតិក្នុងករណីគ្មានជម្រើស

ការសម្រិតសម្រាំងទឹកជ័រតាំងពីការចៀ រហូតដល់ការកែច្នៃគឺជាប្រការសំខាន់ និងចាំបាច់ណាស់ ព្រោះកិច្ចការនោះនាំមកនូវគុណភាពដែលជាកត្តាអាចលើកកម្ពស់តម្លៃ និងទាក់ទាញអតិថិជនទាំងនៅក្នុងប្រទេស និងទាំងនៅលើទីផ្សារអន្តរជាតិ ដែលជួយឲ្យយើងប្រកួតប្រជែងប្រកបដោយនិរន្តរភាពជាមួយនឹងបណ្ដាប្រទេសផលិតកៅស៊ូធម្មជាតិក្នុងពិភពលោក។ ហេតុនេះជ័រកករបស់យើងត្រូវតែស្អាត គ្មានកម្ទេចកម្ទីដី ស្លឹកឈើ ឬលាយនូវសារធាតុមិនល្អផ្សេងៗឡើយ។

ជ័រកកតាមធម្មជាតិ និងបង្កកដោយអាស៊ីតមានគុណភាពខុសៗគ្នា។ ដូចនេះវាជាការចាំបាច់ដែលត្រូវប្រមូលផ្ដុំជ័រទៅតាមប្រភេទរបស់វា។

## ការទុកឲ្យកកតាមធម្មជាតិ

ជ័រអាចកកដោយខ្លួនឯង ដោយប្រើរយៈពេលមួយវែង ដាក់ស្ដែងដូចជា ជ័រចាន ជ័រមុខ ឬជ័រដី។ល។ ការទុកឲ្យទឹកជ័រកកតាមធម្មជាតិ គឺករណីគ្មានជម្រើស ពីព្រោះទឹកជ័រត្រូវបង្កកដោយអាស៊ីត និងកំណត់លក្ខខណ្ឌមិនច្បាស់លាស់ទើបគេទទួលបាននូវគុណភាពប្រសើរ។ ចំពោះទឹកជ័រក្នុងបរិមាណច្រើនការទុកឲ្យកកតាមធម្មជាតិនាំឲ្យខាតទម្ងន់ បាត់បាត់ភាគរយជ័រស្ងួត ដោយសារនៅសល់កៅស៊ូក្នុងសេរ៉ូមច្រើន ព្រមទាំងមានគុណភាពអន់។

ក្នុងករណីខ្លះ គេអាចចៀរជ័រ និងត្រងក្នុងថង់ប្លាស្ទិក




ថ្លារួចទុកឲ្យទឹកជ័រកកដោយឯកឯងក្នុងថង់នោះ រហូតទទួលបានជ័រកកពេញថង់ ទើបប្រមូលម្ដង។ នៅពេលប្រមូល គេត្រូវបកយកថង់ចេញ ឬអាចប្រើឡើងវិញ ប្រសិនបើថង់នៅជាប់មាំល្អ។ វិធីនេះជួយកាត់បន្ថយកម្លាំងពលកម្ម។

## ការបង្កកដោយអាស៊ីត

អាស៊ីតគឺជាសារធាតុដែលមានរស់ជាតិជូរ និងមានច្រើនប្រភេទរាប់មិនអស់។ អាស៊ីតដែលផលិតចេញពីរោងចក្រភាគច្រើន គឺជាអាស៊ីតខាប់ ឬមេអាស៊ីត បើសិនប៉ះនឹងស្បែកវាបង្កគ្រោះថ្នាក់ប្រៀបបាននឹងត្រូវភ្លើងរលាក។ ក្នុងការបង្កកទឹកជ័រគេត្រូវប្រើអាស៊ីតរាវ ដែលបានពីការពង្រាវមេអាស៊ីតក្នុងទឹក។ អាស៊ីតហ្វ័រមិចត្រូវបានគេជ្រើសរើសមកប្រើប្រាស់ដើម្បីបង្កកទឹកជ័រព្រោះវាបានផ្ដល់កកដែលមានគុណភាពល្អ ហើយងាយស្រួលរកបាននូវទីផ្សារ ព្រមទាំងមានតម្លៃសមរម្យ។ គេក៏អាចបង្កកដោយអាស៊ីតអាសេទិចផងដែរ ប៉ុន្តែអាស៊ីតនេះពិបាកនឹងរកទិញហើយមានតម្លៃខ្ពស់។ អាស៊ីតអាគុយ ឬអាស៊ីតភ្លើង គឺជាអាស៊ីតស៊ុលផួរិច ដែលធ្វើឲ្យកៅស៊ូអន់គុណភាព ប៉ះពាល់ដល់សុខភាព និងបរិស្ថាន។

នៅចម្ការកៅស៊ូធំៗ រោងចក្រ និងសិប្បកម្មកៅស៊ូសន្លឹក ការបង្កកធ្វើឡើងក្នុងអាងដែលធ្វើពីបេតុងពាសតដ្ឋការ៉ូ ឬអាងធ្វើអំពីអ៊ីណុក ងាយស្រួលលាងសម្អាត។ ដោយឡែកចំពោះកសិករកៅស៊ូគ្រួសារ ដែលខ្វះខាតមធ្យាបាយការ




បង្កកអាចធ្វើឡើងក្នុងធុងឈើទ្រាប់ដោយប្លាស់ស្ទិកថ្លា (កៅស៊ូថ្លា)ឬក្នុងសំបកកាន ឬធុងប្លាស្ទិក។ល។ ដើម្បីឲ្យជ័រកកស្អាត គេត្រូវគ្របដោយថង់ប្លាស្ទិកថ្លាការពារកម្ទេចកំទីស្លឹកឈើ ឬធូលីដី។ ការជ្រើសរើសសម្ភារសម្រាប់ប្រើប្រាស់ គឺជាការសម្រេចចិត្តរបស់កសិករ។ ទោះជាយ៉ាងណា សម្ភារគួរតែស្អាត ងាយស្រួលលាងសម្អាត ធ្វើឲ្យជ័រកកស្អាត និងមានគុណភាពល្អ។

កសិករត្រូវជៀសវាងការប្រើសំបកបាវប្លាស្ទិកប៉ូលីប្រូពីឡែន ដូចជាបាវស៊ីម៉ង់ត៍ បាវអង្ករ បាវជី និងតង់ប្លាស្ទិក ដោយសារកម្ទេចសរសៃបាវងាយរបេះដាច់ហើយជ្រៀតចូលទៅក្នុងជ័រកក ធ្វើឲ្យកៅស៊ូមានបញ្ហា។ ឧទាហរណ៍អ្នកផលិតសំបកកង់មានការប្រុងប្រយ័ត្នខ្ពស់ចំពោះកៅស៊ូ ដែលមានបង្កប់សរសៃអំបោះ ឬបាវប្លាស្ទិក ព្រោះវាងាយធ្វើផ្ទុះកង់។




ការបង្កកទឹកជ័រក្នុងរណ្តៅដីក៏ជាប្រការមួយ ដែលគេត្រូវជៀសវាងផងដែរ ពីព្រោះកម្ទេចខ្សាច់នឹងតោងជាប់ជាមួយជ័រកក ធ្វើឲ្យកៅស៊ូកខ្វក់។ ទោះបីគេបានទ្រាប់រណ្តៅនេះនឹងថង់ប្លាស្ទិកថ្លាស្អាតយ៉ាងណាក៏កម្ទេចដីនិងខ្សាច់អាចហូរចូលនៅពេលមានភ្លៀងធ្លាក់។

គួរបង្កកទឹកជ័រដោយផ្ចិតផ្ចង់ ប្រកបដោយអនាម័យ ភាពកខ្វក់គឺជាសត្រូវរបស់កៅស៊ូធម្មជាតិ។ កៅស៊ូត្រូវស្អាតសុខភាព និងគុណភាពគឺជាកត្តាសំខាន់។



## ដំណាក់កាលបង្កកទឹកជ័រដោយអាស៊ីត

ដើម្បីបង្កកទឹកជ័រដោយអាស៊ីត គេត្រូវមានសម្ភារសម្រាប់បង្កកដូចបានរៀបរាប់ខាងដើម។ សម្ភារត្រូវលាងសម្អាតឲ្យបានស្អាតល្អ ចៀសវាងកម្ទេចកំទីផ្សេងៗ។

ដំណាក់កាលដំបូង គេត្រូវរៀបចំអាស៊ីតរាវចេញពីអាស៊ីតខាប់ រួចទើបប្រើអាស៊ីតរាវនេះចាក់ចូលក្នុងទឹកជ័រ។

## ការរៀបចំអាស៊ីតហ្វ័រមិចរាវ

អាស៊ីតហ្វ័រមិចដែលគេរកបាននៅលើទីផ្សារ គឺជាអាស៊ីតខាប់ មិនអាចនឹងយកវាទៅប្រើបានភ្លាមនោះទេ ព្រោះវាធ្វើឲ្យទឹកជ័រមិនស្មើសាច់ល្អ ជាពិសេសបង្កគ្រោះថ្នាក់។ ដូច្នេះគេត្រូវពង្រាវអាស៊ីតខាប់ចំណុះ១លីត្រ ជាក្រោយដោយសន្សឹមៗ និងកូឲ្យសព្វល្អ។ គេគួរប្រើស្រោមដៃ ដើម្បីការពារការរលាកដោយអាស៊ីត។ បើសិនគេដាក់មេអាស៊ីតទៅក្នុងធុងមុន នាំឲ្យមានប្រតិកម្មនៅពេលតំណក់ទឹកប៉ះមេអាស៊ីតនោះអាចនាំឲ្យមានគ្រោះថ្នាក់ និងខូចខាតសម្ភារ។




## ការបញ្ចូលអាស៊ីតហ្វ័រមិច

សំដៅដល់ការបញ្ចូលអាស៊ីតមិចរាវ ទៅក្នុងទឹកជ័រធម្មតា ពោលគឺជាទឹកជ័រដែលមិនត្រូវបានលាយទឹក ឬត្រូវបានទឹកភ្លៀងចូល។ ទឹកជ័រត្រូវច្រោះឲ្យស្អាត ដោយមិនឲ្យមានកម្ទេចកំទីដី ស្លឹកឈើ ឬ សំបកឈើផ្សេងៗក្នុងនោះឡើយ។

ខាងក្រោមនេះ គឺជាតារាងនៃបរិមាណអាស៊ីតរាវសម្រាប់បង្កក។

| មាឌទឹកជ័រ (គិតជាលីត្រ) | មាឌអាស៊ីតហ្វ័រមិចរាវ១.៥% (គិតជាលីត្រ) |
|---|---|
| ១០ | ១ |
| ៣០ | ៣ |
| ៥០ | ៥ |
| ១០០ | ១០ |

គេត្រូវចាក់ស្រោចអាស៊ីតទៅក្នុងទឹកជ័រសន្សឹមៗ និងកូរឲ្យសព្វល្អស្របពេលជាមួយគ្នា។ ទុកឲ្យកករយៈពេល៤-៥ម៉ោង យ៉ាងតិចអាចគាស់យកមករក្សាទុក ឬលក់ដូរ ឬកែច្នៃបាន ប៉ុន្តែគេអាចបាត់បង់កៅស៊ូស្ងួតច្រើនទៅក្នុងសេរ៉ូម។ ការបង្កកដែលចប់សព្វគ្រប់ល្អត្រូវការរយៈពេលប្រហែល១៦ ម៉ោង។




គុណភាពនៃការបង្កក អាចឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈសេរ៉ូមពណ៌ខ្ចីថ្លា ឬស្រអាប់បន្តិច ដែលបញ្ជាក់ថា ការបាត់បង់កៅស៊ូមានតិចតួចបំផុត។

## ការរក្សាទុកជ័រកក

គេត្រូវគាស់យកជ័រកកពីសម្ភារបង្កក ដើម្បីចៀសវាងកុំឲ្យជ័រកកនៅត្រាំក្នុងសេរ៉ូម ដែលធ្វើឲ្យកៅស៊ូអន់គុណភាព។

ជ័រកក ត្រូវប្រញាប់យកទៅកែច្នៃ នៅរោងចក្រពីព្រោះការស្តុកទុកយូរធ្វើឲ្យគុណភាពថយចុះជាលំដាប់ ជាពិសេសពន្លឺថ្ងៃ និងការត្រាំទឹក។ គួររក្សាទុកជ័រកកនៅលើរានឈើស្អាត ឬលើសំណាញ់ដែករឹតតែប្រសើរ ដោយលៃយ៉ាងណាមិនឲ្យជាំទឹក មិនឲ្យប៉ះនឹងពន្លឺថ្ងៃ និងមិនមានធូលីដី ឬកម្ទេចកំទីផ្សេងៗចូល។

ចៀសវាងការរុំជ័រកកនឹងសំបកបាវប្លាស្ទិក ដូចជាបាវជី ឬបាវស៊ីម៉ង់ត៍ ឬបាវអង្ករ ។ល។



រានឈើសម្រាប់ផ្ទុកជ័រកក



ជ័រកៅស៊ូទើបប្រមូលពីដើម

